ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៣២ សជណធទឧ

# សេចក្ដីជូនដំណឹង

## ស្ដីពី ស្ថានភាពរបស់ព្យុះទី ៣ ឈ្មោះ ស៊ីនឡាគូ ( SINLAKU )

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ឃើញថា នៅព្រឹកថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០២០ នេះ សម្ពាធទាបសកម្មមួយ ( Active Low ) បានកើតឡើងនៅលើសមុទ្រចិនខាងត្បូង ហើយបានវិវត្តទៅជាវិសម្ពាធទាប ( Tropical Depression ) ។

យោងតាមការព្យាករ វិសម្ពាធទាបនេះ នឹងបង្កើនឥទ្ធិពលរបស់ខ្លួនជាបន្តបន្ទាប់ទៅជាព្យុះទី ៣ ឈ្មោះ **ស៊ីនឡាគូ** ( SINLAKU ) ដោយនឹងធ្វើដំណើរឆ្លងកាត់កោះហៃណាំ មុននឹងចូលដល់ភាគខាងជើងប្រទេសវៀតណាម នៅថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០២០ ។ ឥទ្ធិពលរបស់ព្យុះធ្វើឲ្យខ្យល់មូសុងនិរតីបង្កើនល្បឿនបក់បោកខ្លាំងមកលើកម្ពុជា ។

លក្ខណៈបែបនេះ នឹងធ្វើឲ្យអាកាសធាតុ នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២០ មានស្ថានភាព ដូចខាងក្រោម ៖

១- បណ្ដាខេត្តនៅតំបន់ជាប់ជួរភ្នំដងរែក និងខ្ពង់រាបភាគឦសាន នឹងអាចមានភ្លៀងធ្លាក់ច្រើនកើនឡើងជាបន្តបន្ទាប់ ប្រឈមខ្ពស់នឹងជំនន់ទឹកភ្លៀង ( Flash Flood ) ។

២- តំបន់មាត់សមុទ្រ និងនៅលើផ្ទៃសមុទ្រ នឹងអាចមានភ្លៀងធ្លាក់ច្រើន ប្រឈមខ្ពស់នឹងជំនន់ទឹកភ្លៀង (Flash Flood) រួមជាមួយខ្យល់បក់បោកខ្លាំង និងរលកសមុទ្រខ្ពស់ៗ ។

៣- តំបន់ផ្សេងៗទៀត អាចនឹងមានភ្លៀងធ្លាក់ ពីតិចទៅមធ្យម ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ពិសេសបងប្អូនប្រជានេសាទ និងអ្នកធ្វើដំណើរតាមសមុទ្រទាំងអស់ បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានយ៉ាងយកចិត្តទុកដាក់លើបាតុភូតធម្មជាតិនេះ ហើយនឹងជម្រាបជូនព័ត៌មានជាបន្តបន្ទាប់ទៀត ក្នុងករណីចាំបាច់ ។

ថ្ងៃសុក្រ ១១ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២០

រដ្ឋមន្ត្រី

លឹម_គានហោ

អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥)២៣ ២១៦ ៦៧០
#364 Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670